00640436

E5/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 01 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ:០០២/១៩-០៩-២០០៧-អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **ឆ្វ មណី** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅសៀង
Diana ELLIS
ស សុវាន
Jaques VERGÈS
Philippe GRÉCIANO

## I. សេចក្ដីផ្ដើម

១ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ សហមេធាវីការពារក្ដីរបស់លោក អៀង សារី បានដាក់បណ្ដឹងប្ដឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងដាក់សំណើអមមួយទៀតស្នើសុំឱ្យមានការស៊ើបសួរដោយអនុលោម តាមវិធាន ៣៤, ៤១ និង ៩៣ នៃវិធានផ្ទៃក្នុង[១]។ បណ្ដឹងនោះ ស្នើសុំប្ដឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៣៤ ដោយផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់ចំពោះការប្រព្រឹត្តិខុស ក្នុងអំឡុងពេលគាត់មានតួនាទីជាប្រធានសាលាដំបូងខេត្តបាត់ដំបង នៅមុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ បណ្ដឹងនោះ បានចោទប្រកាន់ថា ក្នុងឆ្នាំ២០០២ លោកប្រធាន និល ណុន ទទួលស្គាល់នៅចំពោះមុខអ្នកថតភាពយន្តឯកសារថា គាត់បាន "ទទួលសគុណជាប្រាក់ពីគូក្ដីដែលបានដឹងគុណគាត់"[២]។ សហមេធាវីការពារក្ដីរបស់លោកអៀង សារី បានប្រឹងប្រែងស្វែងរកខ្សែវីដេអូនេះ ប៉ុន្តែរកមិនបាន ដូច្នេះទើបពួកគាត់ស្នើឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យមានការដាក់បង្ហាញខ្សែវីដេអូនៃកិច្ចសម្ភាសន៍នេះ រួមទាំងឯកសារមួយចំនួនទៀត។ លើសពីនេះទៅទៀត សហមេធាវីការពារក្ដីរបស់លោក អៀង សារី ស្នើសុំឱ្យមានដំណោះស្រាយឆាប់រហ័សមួយ ពាក់ព័ន្ធនឹងបណ្ដឹងនេះ ដោយស្នើសុំឱ្យរៀបចំសវនាការជាសាធារណៈ និងសុំឱ្យលោកចៅក្រម និល ណុន ដកខ្លួនចេញពីកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ នៅខណៈដែលពាក្យបណ្ដឹងនេះ កំពុងរង់ចាំការសម្រេច[៣]។

## II. អំពីការយល់ឃើញ

---

[១] "បណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងជំទាស់ចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថា គាត់បានទទួលស្គាល់ថាគាត់បានទទួលយកសំណូក និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ឬជម្រើសផ្សេងពីនេះអនុញ្ញាតឱ្យដាក់ចម្លើយតបទៅនឹងអំណះអំណាងនានាដាក់ដោយចៅក្រម និល ណុន ជាកិច្ចឆ្លើយតបទៅនឹងពាក្យបណ្ដឹងនេះ" ឯកសារ (E5) ("ពាក្យបណ្ដឹង") និង "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងបណ្ដឹងរបស់លោក អៀង សារី សុំប្ដឹងជំទាស់ចិត្តចៅក្រម និល ណុន ដោយសារគេយល់ឃើញថា គាត់បានទទួលស្គាល់ថា គាត់បានទទួលយកសំណូក ដោយស្នើសុំ ឬចេញដីកាបង្គាប់ឱ្យអ្នកផលិតភាពយន្ត AMANDA PIKE ឱ្យលាតត្រដាងបង្ហាញខ្សែភាពយន្តនៃកិច្ចសម្ភាសន៍របស់គាត់ជាមួយចៅក្រម និល ណុន និងលិខិតអនុញ្ញាតឱ្យចាក់ផ្សាយដែលមានហត្ថលេខារបស់លោក និល ណុន" ដាក់ឯកសារនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ឯកសារ(E6) ("សំណើសុំ")

[២] ពាក្យបណ្ដឹង បុព្វកថា ទំព័រ១។

[៣] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២-៥។

ក.  <u>ពេលនៃការដាក់ពាក្យប្ដឹង</u>

២  វិធាន ៣៤(៤)(គ) នៃវិធានផ្ទៃក្នុងចែងថា ពាក្យបណ្ដឹងជំទាស់ចំពោះចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អាចប្ដឹង “នឹងបញ្ហាពាក់ព័ន្ធដែលលេចឡើងមុនពេលជំនុំជម្រះ នៅពេលសវនាការបឋម ឬពាក់ព័ន្ធនឹងបញ្ហាកើតឡើងក្នុងអំឡុងពេលជំនុំជម្រះ ឬកាលណាភាគីមិនបានដឹងនៅមុនពេលជំនុំជម្រះ នៅមុនពេលធ្វើសេចក្ដីសម្រេចចុងក្រោយលើសំណុំរឿងនោះ”[៤]។ ផ្ទុយទៅវិញ វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បង្គាប់ឲ្យភាគីដែលធ្វើបណ្ដឹងជំទាស់ ដាក់ពាក្យបណ្ដឹងឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ។ សហមេធាវីការពារក្ដីរបស់លោក អៀង សារី បានសម្រេចជ្រើសរើសដាក់ពាក្យបណ្ដឹងជំទាស់នេះ នៅមុនសវនាការបឋម។ អង្គជំនុំជម្រះ យល់ស្របជាមួយសហមេធាវីការពារក្ដីរបស់លោក អៀង សារី ថា (ក្នុងន័យនៃកាតព្វកិច្ចនៃការយកចិត្តទុកដាក់ហ្មត់ចត់របស់គូភាគី និង ដើម្បីផលប្រយោជន៍នៃការរៀបចំការជំនុំជម្រះក្ដីប្រកបដោយប្រសិទ្ធភាព) ពាក្យបណ្ដឹងនេះគប្បីត្រូវយកមកសម្រេចឲ្យបានឆាប់រហ័ស[៥]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ពាក្យបណ្ដឹងនេះ ដាក់ត្រូវពេលវេលា។ សហព្រះរាជអាជ្ញាខកខានមិនបានប្រើប្រាស់ឱកាសរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងបណ្ដឹងជំទាស់ក្នុងអំឡុងពេលកំណត់ទេ។ សំណើសុំពន្យាពេលរបស់សហព្រះរាជអាជ្ញាធ្វើឡើងមិនមានភាពច្បាស់លាស់អំពីពេលណានោះទេ ដែលតាមវិធានផ្ទៃក្នុង ចៅក្រមមានសិទ្ធិធ្វើសារណាតបចំពោះបណ្ដឹងជំទាស់នោះ។ ប៉ុន្តែ នៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១១ លោកចៅក្រម និល ណុន បានបញ្ជាក់ថា លោកមិនមានបំណងធ្វើសារណាតបចំពោះបណ្ដឹងជំទាស់នោះទេ តាមវិធាន ៣៤(៧) នៃវិធានផ្ទៃក្នុង។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងគប្បីបដិសេធសំណើសុំពន្យាពេលរបស់សហព្រះរាជអាជ្ញា ក្នុងគោលបំណងធានានូវការពន្លឿននីតិវិធី។

ខ.  <u>សំណើសុំធ្វើសវនាការជាសាធារណៈ និង សំណើសុំឲ្យដកខ្លួនចេញពីបញ្ហាដែលកំពុងរង់ចាំការសម្រេច</u>

៣  នីតិវិធីដែលមានចែងក្នុងវិធាន ៣៤(៧) តម្រូវឲ្យអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរមួយ ដោយផ្អែកលើបញ្ហានៃបណ្ដឹងជំទាស់នេះ និងសារណារបស់ចៅក្រម ប្រសិនបើមាន។ វិធាននេះពុំមានចែងច្បាស់លាស់អំពីការធ្វើសវនាការនោះទេ ចំណែកឯច្បាប់របស់ព្រះរាជាណាចក្រ

---

[៤] សាលដីកាលើពាក្យបណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង (សាធារណៈ) សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/អបជ(០៩) ឯកសារលេខ៨ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ (“សាលដីកាលើពាក្យបណ្ដឹងជំទាស់ចៅក្រម *យូ ប៊ុនឡេង*”) កថាខណ្ឌ១២។

[៥] ពាក្យបណ្ដឹង កថាខណ្ឌ១-២។

កម្ពុជាក៏ពុំតម្រូវឲ្យមានសវនាការនោះដែរ[៦]។ ដូចគ្នានេះដែរ តាមទម្លាប់ សាលាក្តីអន្តរជាតិដទៃទៀតសម្រេចសេចក្តីលើបណ្តឹងស្រដៀងគ្នានេះ គឺផ្អែកលើតែសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ[៧]។ អង្គជំនុំជម្រះយល់ឃើញថា គប្បីចាត់ការលើបណ្តឹងនេះឲ្យបានឆាប់រហ័ស ដើម្បីជាប្រយោជន៍យុត្តិធម៌។ អង្គជំនុំជម្រះ នឹងធានាមានតម្លាភាពនៃនីតិវិធីទាំងនេះ ដោយការប្តូរចំណាត់ថ្នាក់នៃឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង និងសំណើនេះ ឲ្យក្លាយទៅជាឯកសារសាធារណៈ។

៤ វិធាន ៣៤(៦) នៃវិធានផ្ទៃក្នុងចែងថា ចៅក្រមដែលត្រូវគេប្តឹងជំទាស់ ត្រូវជំនួសដោយចៅក្រមបម្រុង សម្រាប់តែករណីនៃបណ្តឹងជំទាស់នេះប៉ុណ្ណោះ។ អនុលោមតាមវិធាន ៣៤(៥) ចៅក្រមដែលត្រូវគេប្តឹងជំទាស់ អាចបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់នេះ។ ប៉ុន្តែចៅក្រមនោះ អាចសម្រេចចិត្តលាលែងដោយស្ម័គ្រចិត្តបាន។ ផ្ទុយពីអ្វីដែលបានចោទប្រកាន់នៅក្នុងពាក្យបណ្តឹងជំទាស់ សេចក្តីសម្រេចទាំងឡាយរបស់អង្គជំនុំជម្រះនឹងមិនត្រូវចាត់ទុកជាមោឃៈបានទេ ទោះបីជាក្រោយមក ចៅក្រមនោះត្រូវបានគេដកចេញក៏ដោយ[៨]។

គ. <u>ក្របខ័ណ្ឌច្បាប់</u>

៥ សិទ្ធិទទួលបាននូវតុលាការមួយឯករាជ្យ និងឥតលម្អៀង គឺជាធាតុសំខាន់នៃសិទ្ធិជាសារវ័ន្ត ដើម្បីទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌[៩]។ ឆ្លើយតបទៅនឹងចំណុចនេះ វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា៖

---

[៦] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CCP") មាត្រា៥៦១ ("មិនចាំបាច់ស្តាប់ភាគីឬចៅក្រមពាក់ព័ន្ធទេ") និងសាលដីកាលើពាក្យបណ្តឹងជំទាស់ចៅក្រម *ន័យ ធុល* កថាខណ្ឌ៨។

[៧] *សូមមើល ឧទាហរណ៍រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Karemera និងអ្នកផ្សេងទៀត, សេចក្តីសម្រេចស្តីពីបណ្តឹងជំទាស់របស់* Joseph Nzirorera សុំប្តឹងជំទាស់ចៅក្រម Byron, Kam និង Joensen, ការិយាល័យ ICTR (ICTR-98-44-T), ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០០៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin និងTalić, សេចក្តីសម្រេចស្តីពីបណ្តឹងរបស់* Momir Talić សុំប្តឹងជំទាស់ និងសុំដកចៅក្រម អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY (IT-99-36-PT), ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០០ ("សេចក្តីសម្រេចក្នុងរឿងក្តី *Brđanin និង Talić*")។

[៨] វិធានផ្ទៃក្នុង៣៤(៨)។ ប្រៀបធៀបពាក្យបណ្តឹង កថាខណ្ឌ៤។

[៩] *សូមមើល* មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Karemera និងអ្នកផ្សេងទៀត សេចក្តីសម្រេចលើបណ្តឹងរបស់* Karemera សុំប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង, បណ្តឹងប្តឹងជំទាស់ចៅក្រម និល ណុន /ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១/សាធារណៈ:

CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C B T C

ភាគីអាចធ្វើបណ្តឹងជំទាស់ចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឲ្យមានភាពលម្អៀង។

៦ យុត្តិសាស្ត្រនៃ អ.វ.ត.ក ដែលបកស្រាយពាក់ព័ន្ធនឹងវិធាននេះ បានអនុវត្តលក្ខណៈវិនិច្ឆ័យមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY និងចែងថា៖

> ចៅក្រមមួយរូប ត្រូវបានចាត់ទុកថាមានភាពលម្អៀង ប្រសិនបើគេរកឃើញអត្ថិភាពនៃមូលដ្ឋានលម្អៀងនោះពិតប្រាកដមែន។
>
> អត្ថិភាពនៃភាពលម្អៀងស្តែងចេញឲ្យឃើញ ក្នុងករណីដែល៖
>
> • ចៅក្រមរូបនោះជាភាគីនៃរឿងក្តី ឬ មានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬ ទាក់ទងនឹងកម្មសិទ្ធិដែលបានមកពីរឿងក្តី ឬ ប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមនោះ នឹងនាំឲ្យមានការជួយជំរុញដល់ហេតុនៃរឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធនឹងភាគីណាមួយក្នុងរឿងក្តីនោះ[១០]។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះត្រូវតែដកចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
>
> • កាលៈទេសៈបណ្តាលឲ្យអ្នកសង្កេតការណ៍ដែលមានសុភវិនិច្ឆ័យ និង ដែលទទួលបានព័ត៌មានត្រឹមត្រូវ អាចយល់បានដោយសមហេតុផល ថាមានភាពលម្អៀង[១១]។

---

ការិយាល័យរបស់ ICTR (ICTR-98-44-T), ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ៧ (“សេចក្តីសម្រេច *Karemera* ឆ្នាំ ២០០៤”)។

[១០] លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានអនុម័ត និងបកស្រាយដោយតុលាការអន្តរជាតិដទៃទៀត៖ សូមមើល ឧទាហរណ៍ លក្ខន្តិកៈក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ (ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២), 2187 UNTS 90, មាត្រា 41(2)(ក) និងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC អនុម័តថ្ងៃទី៣-១០ ខែកញ្ញា ឆ្នាំ២០០២, ICC-ASP/1/3, វិធាន 34(1) (អានផ្ទួបគ្នាជាមួយនឹងឃ្លាថា តម្រូវឲ្យប្រកាសជំទាស់ចៅក្រមមួយរូបណា ដែលភាពលម្អៀងរបស់គាត់ “អាចមានហេតុផលសមស្របណាមួយឲ្យគេមានសង្ស័យ” រួមទាំងការពាក់ព័ន្ធពីមុនណាមួយជាមួយ ឬ ផលប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងករណីនោះ, ទំនាក់ទំនងណាមួយជាមួយនឹងគូភាគី ឬតំណែងដែលគាត់មាន ឬគំនិតដែលបញ្ចេញមិនស៊ីគ្នានឹងភាពអនាគតិរបស់គាត់)។ វិធាន ១៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងនៃសាលាក្តី ICTY និង ICTR មានខ្លឹមសារដូចគ្នា។ សូមមើលបន្ថែម រឿងក្តី ព្រះរាជអាជ្ញា ទល់នឹង *Norman*, សេចក្តីសម្រេចស្តីពីញត្តិសុំឲ្យចៅក្រម Winter ដកខ្លួនចេញពីការពិភាក្សាសម្រេច នៅក្នុងញត្តិបឋមស្តីពីការរើសទាហានកុមារ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការពិសេសនៃប្រទេសសេរ៉ាឡេអូន (SCSL-2004-14), ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ កថាខណ្ឌ ២៨។

[១១] សាលដីកាលើពាក្យបណ្តឹងជំទាស់ចៅក្រម *ន័យ ធុល* កថាខណ្ឌ២០-២១ (ប្រៀបធៀប “អ្នកសង្កេតការណ៍ដែលមានសុភវិនិច្ឆ័យ” ជាមួយនឹង “បុគ្គលម្នាក់ដែលមានព័ត៌មានគ្រប់គ្រាន់ ដោយមានការយល់ដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់”)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

៧ យុត្តិសាស្ត្រនៃ អ.វ.ត.ក កត់សម្គាល់បន្ថែមទៀតថា បណ្ដឹងជំទាស់ចៅក្រមត្រូវឲ្យប្ដឹងបានចំពោះតែចៅក្រមជាក់លាក់ណាម្នាក់ ដែលកំពុងដោះស្រាយរឿងក្ដីជាក់លាក់ណាមួយប៉ុណ្ណោះ មិនមែនប្ដឹងជំទាស់ចំពោះករណីទូទៅនោះទេ[១២]។ អាស្រ័យហេតុនេះ បណ្ដឹងជំទាស់ តាមវិធាន ៣៤ ដែលផ្អែកលើការចោទប្រកាន់នៃការប្រព្រឹត្តិខុសឆ្គងក្នុងរឿងក្ដីផ្សេង នឹង មិនទទួលជោគជ័យទេ លើកលែងតែមានភស្តុតាងបង្ហាញថា កំហុសនោះនឹងរារាំងមិនឲ្យចៅក្រមរូបនោះអនុវត្តបាននូវ "គំនិតអនាគតិ និង ភាពមិនបុរេវិនិច្ឆ័យ" ក្នុងរឿងក្ដីដែលខ្លួនកំពុងចាត់ការ[១៣]។ លើសពីនេះទៅទៀត ការរកឃើញភាពលម្អៀងក្នុងរឿងក្ដីមួយ គឺមិនតម្រូវឲ្យចៅក្រមរូបនោះដកខ្លួន ចំពោះរឿងក្ដីដទៃទៀត ឬរឿងក្ដីដែលមិនពាក់ព័ន្ធនោះទេ[១៤]។

---

រាប់បញ្ចូលទាំងប្រពៃណីនៃសេចក្ដីថ្លៃថ្នូរ និងភាពមិនលម្អៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបត្រូវតែសច្ចាថាគាំទ្រលើកតម្កើង")។ *រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង* Furundžija សាលដីកាសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (IT-95-17/1-A) ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ១៨៩ ("សាលដីកា សាលាឧទ្ធរណ៍ករណី*Furundžija*")។ *សូមមើលផងដែរ រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកផ្សេងទៀត*, សេចក្ដីសម្រេចស្ដីពីញត្តិរបស់ Sesay និង Gbao សុំឲ្យចៅក្រម Bankole Thompson ដកខ្លួនចេញដោយស្ម័គ្រចិត្តពីសំណុំរឿង RUF ឬសុំប្ដឹងជំទាស់ចៅក្រមគាត់, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេសនៃប្រទេសសេរ៉ាឡេអូន (SCSL-04-15-T-909), ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ 51។ សេចក្ដីសម្រេច *Karemera* ឆ្នាំ២០០៤, កថាខណ្ឌ ៨។ សេចក្ដីសម្រេចស្ដីពីញត្តិរបស់លោក El Sayed "សុំប្ដឹងជំទាស់ចៅក្រម Riachy ពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ អនុលោមតាមវិធាន 25, STL President (CH/PRES/ 2010/ 08), ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ 11, 19។

[១២] វិធានផ្ទៃក្នុង៣៤(២)។ *សូមមើលផងដែរ* សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ថុល ឯកសារ C11/29 ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ("សាលដីកាករណីចៅក្រម *ន័យ ថុល*") កថាខណ្ឌ៩-១១។ *សូមមើលផងដែររឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត*, សេចក្ដីសម្រេចរបស់ the Bureau ស្ដីពីញត្តិសុំប្ដឹងជំទាស់ចៅក្រមមួយចំនួន ដោយអនុលោមតាមវិធាន ១៥ ឬអាចជំនួសដោយជម្រើសនៃការសុំដកខ្លួនដោយខ្លួនឯងពីសំណាក់ចៅក្រមទាំងនោះវិញក៏បាន, ការិយាល័យ ICTY (IT-96-21-T), ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៦ កថាខណ្ឌ 8-9 (ភាពខុសគ្នារវាងសេចក្ដីសម្រេចផ្នែករដ្ឋបាល ទី១គឺត្រង់ថាតើជនម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីជាចៅក្រមបានដែរឬយ៉ាងណា ទី២អំពីពាក្យប្ដឹងសុំជំទាស់ចៅក្រមពាក់ព័ន្ធនឹងភាពលម្អៀងរបស់ចៅក្រមរូបនោះ ទាក់ទិន *ករណីជាក់លាក់មួយ* (សេចក្ដីបញ្ជាក់បន្ថែម មាននៅក្នុងច្បាប់ដើម)។

[១៣] សេចក្ដីសម្រេចក្នុងរឿងក្ដី *Brđanin* និង *Talić*, កថាខណ្ឌ ១៩។

[១៤] សូមមើលករណី *Bracy ទល់នឹង Gramley*, 520 U.S. 899, 909 (1997) (ជនជាប់ចោទមានសិទ្ធិសុំឲ្យស្រាវជ្រាវលាតត្រដាង ពាក់ព័ន្ធនឹងបែបបទនៃការទទួលសំណូករបស់ចៅក្រម ក្នុងករណីផ្សេង ដោយសារតែគាត់ផ្ដល់ហេតុផលដែលគួរឱ្យជឿជាក់បាន និងមានភស្តុតាងគាំទ្រ អំពីថាតើហេតុអ្វីបានជាបែបបទនោះបង្ហាញឲ្យឃើញ "ភាពលម្អៀងពិតប្រាកដ *ក្នុងករណីរបស់ម្ចាស់បណ្ដឹងផ្ទាល់*") (សេចក្ដីបញ្ជាក់បន្ថែម មាននៅក្នុងច្បាប់ដើម)។ រឿងក្ដី *Cartalino ទល់នឹង. Washington*, 122

៨ ដូច្នេះ វិធាន ៣៤ និងយុត្តិសាស្ត្រខាងលើបង្ហាញថា បណ្តឹងជំទាស់ដែលពាក់ព័ន្ធនឹងភាពលម្អៀង ចំពោះជនជាប់ចោទជាក់លាក់មួយរូបទាក់ទិននឹងរឿងក្តីជាក់លាក់មួយ បណ្តឹងជំទាស់នោះមិនអាចយកទៅប្រើប្រាស់ ដើម្បីប្តឹងជាលក្ខណៈទូទៅស្តីពីលក្ខណៈសម្បត្តិរបស់បុគ្គលម្នាក់ ដើម្បីបំពេញតួនាទីជាចៅក្រមនោះបានទេ។

៩ ប៉ុន្តែ លំនាំនៃការប្រព្រឹត្តិមិនត្រឹមត្រូវ អាចជាបញ្ហានៃការជំទាស់ចំពោះបុគ្គលដែលបំពេញតួនាទីជាចៅក្រមនៅ អ.វ.ត.ក បាន[15]។ ច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង ពុំមានចែងអំពីយន្តការដែលពាក់ព័ន្ធណាមួយឡើយ។ អ.វ.ត.ក ពុំមែនជាអ្នកតែងតាំងចៅក្រមជាតិដោយផ្ទាល់នោះទេ។ អ្នកដែលតែងតាំងចៅក្រមជាតិដោយផ្ទាល់ គឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[១៦]។ ដូច្នេះ យន្តការដើម្បីសម្រេចថា តើបុគ្គលម្នាក់មានលក្ខណៈសម្បត្តិ ដើម្បីបំពេញតួនាទីជាចៅក្រមជាតិបាន ឬមិនបាននៅចំពោះមុខ អ.វ.ត.ក គឺស្ថិតនៅក្នុងច្បាប់ជាតិ។

## ឃ. សំអាងហេតុ

### *i- មូលដ្ឋាននៃបណ្តឹង*

១០ ការចោទប្រកាន់ដែលមាននៅក្នុងបណ្តឹងជំទាស់នេះ គឺពាក់ព័ន្ធនឹងរយៈកាលមួយ នៅមុនពេលបង្កើត អ.វ.ត.ក។ នៅក្នុងពាក្យបណ្តឹងជំទាស់នេះទៀតសោត មិនបានចោទប្រកាន់អំពីការប្រព្រឹត្តិខុសពាក់ព័ន្ធនឹងសំណុំរឿង ០០២ ឡើយ។ តាមពិត ពាក្យបណ្តឹងនេះគ្រាន់តែទទួលស្គាល់ថា ការប្រព្រឹត្តិ

F.3d 8, 10 (7th Cir. 1997) (មួយខែបន្ទាប់ពីការយល់ឃើញរបស់តុលាការកំពូលក្នុងរឿងក្តី *Bracy,* មានការបញ្ជាក់ឡើងវិញថា "ការពិតមួយដែលថា ចៅក្រមមួយរូបទទួលសំណូកក្នុងករណីខ្លះ មិននាំឱ្យគេយល់ថា គាត់គ្មានភាពអព្យាក្រឹតក្នុងករណីផ្សេងទៀតនោះទេ។ [...] វាគឺជាកាលៈទេសៈដែលគួរឱ្យសង្ស័យ ដែលតម្រូវឱ្យមានការស៊ើបអង្កេត")។

[១៥] *សូមមើលឧទាហរណ៍* មាត្រា១០ នៃច្បាប់អ.វ.ត.ក (ចៅក្រមទាមទារឱ្យមាន "ចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត ដែលត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ។")

[១៦] ច្បាប់អ.វ.ត.ក មាត្រា១១ថ្មី។ ការតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានការយល់ព្រមពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា: *សូមមើល*ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២១៤ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦។ "ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម" ព្រះរាជក្រម លេខ០៥ នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ មាត្រា១១ ("ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេច និងលើកសេចក្តីស្នើសុំថ្វាយព្រះមហាក្សត្រលើការតែងតាំង ការផ្លាស់ប្តូរ ការផ្អាកពីមុខងារ ការដាក់ឱ្យនៅទំនេរ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌ ការហាមឃាត់ការងារចៅក្រម និងវិធានព្រះរាជអាជ្ញាទាំងអស់ ")។



CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

បែបនេះទំនងជាមិនអាចកើតមាននៅក្នុងលក្ខណៈពិសេសនៃ អ.វ.ត.ក នោះទេ[១៧]។ ដោយចង្អុលបង្ហាញនូវបទប្បញ្ញត្តិនៃច្បាប់ជាតិ និងអន្តរជាតិនានាដែលគេទទួលស្គាល់ អំពីគោលការណ៍ឯករាជ្យភាព ភាពសុចរិត និងអនាគតិរបស់តុលាការ[១៨] ប៉ុន្តែពាក្យបណ្តឹងនេះ បែរជាសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃគោលការណ៍ទាំងបី ទាំងការយល់ឃើញអំពីការជំនុំជម្រះក្តីប្រកបយុត្តិធម៌ក្នុងរឿងក្តីជាក់លាក់មួយចំនួន និងទាំងភាពសុចរិត និងជំនឿទុកចិត្តពីសាធារណជនលើប្រព័ន្ធតុលាការជាទូទៅ ទៅវិញ[១៩]។

១១. អង្គជំនុំជម្រះ យល់ស្របថា ការធានាឯករាជ្យភាពរបស់តុលាការ គឺពិតជាមានសារៈសំខាន់ខ្លាំង និងជាមូលដ្ឋានស្នូល ដើម្បីលើកកម្ពស់ និងរក្សាបាននូវជំនឿទុកចិត្តពីសាធារណជនលើប្រព័ន្ធតុលាការ[២០]។ ប៉ុន្តែ គោលការណ៍ទាំងនេះមាននភាពខុសគ្នាពីលក្ខណៈវិនិច្ឆ័យនៅចំពោះមុខ អ.វ.ត.ក និង សាលាក្តីអន្តរជាតិដទៃទៀតអំពីការប្តឹងជំទាស់ចៅក្រមនេះ។ ដូចបានចង្អុលបង្ហាញខាងលើ គោលបំណងរបស់បទប្បញ្ញត្តិស្តីពីបណ្តឹងជំទាស់នេះ គឺដើម្បីធានានូវអនាគតិរបស់ចៅក្រមមួយរូប ក្នុងរឿងក្តីមួយជាក់លាក់ប៉ុណ្ណោះ។ ដូច្នេះ វិសាលភាពនៃវិធាន ៣៤ នៃវិធានផ្ទៃក្នុង គឺអនុវត្តបានចំពោះតែស្ថានភាពដែលការចោទប្រកាន់នៃការប្រព្រឹត្តិមិនត្រឹមត្រូវនោះ បង្ហាញនូវផលប៉ះពាល់ទៅលើរឿងក្តីមួយជាក់លាក់ប៉ុណ្ណោះ។ ចំណែកឯយន្តការទាក់ទិនក្នុងបរិបទ អ.វ.ត.ក ស្តីពីការចោទប្រកាន់ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិរបស់បុគ្គលម្នាក់ ដើម្បីបំពេញតួនាទីជាចៅក្រមបាន ឬមិនបាននោះ គឺមានចែងនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា[២១]។

---

[១៧] ពាក្យបណ្តឹង កថាខណ្ឌ៣២។

[១៨] ពាក្យបណ្តឹង កថាខណ្ឌ១៤-២៤ ទាញសំអាងហេតុ *ក្នុងចំណោមរឿងផ្សេងទៀត* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា៣(៣)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤(១)។ ក្រមសីលធម៌តុលាការ អ.វ.ត.ក អនុម័តនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ និងធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា១-៣។ គោលការណ៍នៃការប្រព្រឹត្តិរបស់តុលាការ Bangalore ឆ្នាំ២០០២, Values 1-4។

[១៩] ពាក្យបណ្តឹង កថាខណ្ឌ៣០-៣៧។

[២០] *សូមមើលឧទាហរណ៍ "គណនេយ្យភាព និងសមត្ថកិច្ចរបស់ចៅក្រម" នៅក្នុងរបាយការណ៍ពិភពលោកស្តីពីអំពើពុករលួយ ឆ្នាំ២០០៧ (អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ២០០៧)* ទំព័រ៤០-៦៦។

[២១] កិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក មិនបានផ្តល់យន្តការណាមួយឲ្យ អ.វ.ត.ក តែងតាំង ដាក់វិន័យ ឬដកហូតចៅក្រមកម្ពុជា ដោយផ្ទាល់នោះទេ (ដូចខាងលើ កថាខណ្ឌ ៩)។ យន្តការនេះកើតចេញពីចរិតលក្ខណៈតុលាការរបស់ អ.វ.ត.ក ដែលផ្តល់ការ បណ្តឹងប្តឹងជំទាស់ចៅក្រម និល ណុន /ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១/សាធារណៈ

### *ii. យន្តការដើម្បីធានាសុចរិតភាពរបស់តុលាការ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា និងតួនាទីរបស់ អ.វ.ត.ក*

១២. អ.វ.ត.ក គឺជាតុលាការមួយដែលត្រូវបានបង្កើតឡើងក្នុងរចនាសម្ព័ន្ធតុលាការរបស់កម្ពុជា បើទោះបីជាវាមានលក្ខណៈពិសេសក៏ដោយ[២២]។ ដូចគ្នាទៅនឹងយុត្តាធិការជាតិរបស់ប្រទេសជាច្រើនដែរ ឯករាជ្យភាពរបស់តុលាការត្រូវបានចែងជាគោលការណ៍សារវ័ន្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣[២៣]។ ក្រមសីលធម៌ចៅក្រម[២៤] ចែងបន្ថែមទៀតថា ចៅក្រមត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ឯករាជ្យភាព និងភាពសុចរិត[២៥]។ ក្រមសីលធម៌នេះរួមមានគោលការណ៍ទាក់ទងនឹងការទទួលយកអំណោយផ្សេងៗផងដែរ[២៦]។ អនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ[២៧]។ ការតែងតាំងចៅក្រមត្រូវបានធ្វើឡើង បន្ទាប់ពីមានសេចក្តីស្នើថ្វាយពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[២៨]។ ដូចមាននៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើន ទោះបីជាមានការធានាមិនឱ្យមានការដកហូតមុខងារ

---

ទទួលខុសត្រូវអំពីឯករាជ្យភាពនេះទៅឲ្យរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅក្នុងការតែងតាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិទៅវិញទេ។

[២២] មាត្រា ២ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[២៣] មាត្រា ១២៨(ថ្មី) នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ចែងថា៖ “អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ”។

[២៤] បោះឆ្នោតដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៧ និងឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។

[២៥] ទោះជាយ៉ាងក៏ដោយ ក្រមសីលធម៌ចៅក្រមនេះមិនបានចែងពីផលវិបាក ឬការដាក់ទណ្ឌកម្មនោះទេ ក្នុងករណីចៅក្រម ឬព្រះរាជអាជ្ញាមិនគោរពតាមគោលការណ៍ទាំងនេះ។ ប៉ុន្តែ លទ្ធភាពនៃការដកខ្លួនចេញពីរឿងក្តីមួយមានចែងក្នុងមាត្រា ១៧។

[២៦] ក្រមសីលធម៌ចៅក្រម មាត្រា ២០ (ការទទួលយកអំណោយ ចែងថា៖ “ចៅក្រមត្រូវបែងចែកឲ្យបានច្បាស់លាស់នូវ អំណោយដែលជូនឲ្យខ្លួនជាលក្ខណៈបុគ្គលពីមិត្តភក្តិជិតស្និទ្ធ ឬ បងប្អូនសាច់ញាតិ និង អំណោយដែលជូនឲ្យខ្លួនជាលក្ខណៈផ្លូវការ។ បញ្ហានឹងមិនមានទេ ប្រសិនបើចៅក្រមទទួលយកអំណោយជាលក្ខណៈបុគ្គល និងមានតម្លៃតិចតួច ហើយមិនមានការពាក់ព័ន្ធនឹងមុខតំណែងតុលាការ ឬអយ្យការ។ ចៅក្រមមិនត្រូវប្រើមុខតំណែងរបស់ខ្លួន ដើម្បីទាក់ទាញយកអំណោយ ការជប់លៀង ការខ្ចី ឬការបំពេញចិត្តអ្វីឡើយ។ ប៉ុន្តែ ចៅក្រមអាចទទួលយកនូវអំណោយដោយសារខ្លួនបានធ្វើបទឧទ្ទេសនាមទទួលភ្ញៀវបរទេស ឬចូលរួមក្នុងកម្មវិធីផ្សេងៗ ប្រសិនបើអំណោយនោះមើលទៅឃើញថា មិនមានលក្ខណៈធំដុំអាចទទួលយកបាន”។ (បកប្រែក្រៅផ្លូវការ)។

[២៧] មាត្រា ១៣២(ថ្មី) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា៖ “ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យភាពនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ”។

[២៨] មាត្រា ១៣៤(ថ្មី) កថាខណ្ឌ៣ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា៖ “ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ស្នើរសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងអង្គចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្តីទាំងអស់។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

ចៅក្រមតាមទំនើងចិត្តក៏ដោយ ក៏វានៅតែជាការទទួលខុសត្រូវរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការសម្រេចដាក់វិន័យចៅក្រមដែលបានប្រព្រឹត្តខុស[២៩]។ លើសពីនេះទៀត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានអំណាច "សម្រេច និងលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំង ការផ្ទេរ ការដកហូតពីមុខងារ ការព្យួរការងារ ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ ឬការដកហូតមុខដំណែងពីចៅក្រម និង ព្រះរាជអាជ្ញា"[៣០]។ ដូច្នេះ ចៅក្រមកម្ពុជាត្រូវគោរពករណីយកិច្ចដែលមានចែងនៅក្នុងក្រមសីលធម៌ចៅក្រម ហើយការទទួលខុសត្រូវក្នុងការត្រួតពិនិត្យនិងការអនុវត្តនូវករណីយកិច្ចទាំងនេះគឺជាតួនាទីរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

១៣. ដូចគ្នាទៅនឹងប្រទេសជាច្រើនដែលទន់ខ្សោយដោយសារតែសង្គ្រាមស៊ីវិល ការអនុវត្តនូវបទប្បញ្ញត្តិច្បាប់ឲ្យបានល្អ គឺត្រូវការពេលវេលា ហើយច្បាប់ខ្លះទើបតែត្រូវបានអនុម័ត[៣១]។ ច្បាប់មួយចំនួនទៀតកំពុងតែធ្វើការកែលំអ ហើយបទដ្ឋាននៅក្នុងផ្នែកនេះកំពុងតែមានការវិវឌ្ឍន៍[៣២]។ ស្ថានភាពនៃការចុះខ្សោយនៃប្រព័ន្ធច្បាប់នេះ ត្រូវបានគេមើលឃើញនៅក្នុងប្រព័ន្ធច្បាប់នានាជាច្រើនដែលក្នុងនោះមានប្រទេសកម្ពុជាដែលចេញពីរបបកម្ពុជាប្រជាធិបតេយ្យផងដែរ[៣៣]។ ចំណុចខ្សោយនេះ

---

[២៩] មាត្រា ១៣៣(ថ្មី) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣: "ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ។ ប៉ុន្តែ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស"។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យត្រូវប្រជុំក្រោមអធិបតីនៃប្រធានតុលាការកំពូល (មាត្រា ១៣៤(ថ្មី) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ កថាខណ្ឌ៤)។

[៣០] បកប្រែក្រៅផ្លូវការ។

[៣១] ឧទាហរណ៍ សញ្ញាណនៃការប្រព្រឹត្តខុសរបស់ចៅក្រមក៏មិនបានចែងឲ្យបានច្បាស់លាស់ដែរ ទាំងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទាំងនៅកន្លែងផ្សេងទៀត (*សូមមើលឧទាហរណ៍* ច្បាប់លេខ០៩ នស.៩៤។ សូមមើលមាត្រា ១៣៥(ថ្មី) នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា៖ "លក្ខន្តិកៈនៃអង្គចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា"។

[៣២] *សូមមើលឧទាហរណ៍៖ របាយការណ៍របស់រដ្ឋាភិបាលកម្ពុជាផ្ញើជូនគណៈកម្មាធិការសិទ្ធិមនុស្សក្នុងឆ្នាំ ១៩៩៣* (ICCPR/C/81/Add.12, ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៨), E9/6.8, ERN (Fr) 00333208, កថាខណ្ឌ ២១២, *របាយការណ៍របស់លោក Michael Kirby (ជនជាតិអូស្ត្រាលី) ដែលជាតំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិផ្ញើជូនគណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងឆ្នាំ ១៩៩៤*, E/CN.4/1994/73, E9/6.6, ERN (Fr) 00333197, 00333198, កថាខណ្ឌ ១៣៧ និងកថាខណ្ឌ ១៥៥។

[៣៣] កង្វះសមត្ថភាពរបស់តុលាការជាតិ គឺពិតជាកម្លាំងរុញច្រានមួយដែលនាំឲ្យរាជរដ្ឋាភិបាលកម្ពុជាស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីបង្កើត អ.វ.ត.ក នៅក្នុងឆ្នាំ ១៩៩៧។ *សូមមើល* លិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ពីរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីស៊ើបអង្កេត និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានបញ្ជាក់យ៉ាងច្បាស់ទៅលើមូលដ្ឋានដែលថា ប្រទេសកម្ពុជា "មិនមានធនធាន ឬជំនាញ" ដើម្បីធ្វើការកាត់សេចក្តីបែបនេះបានទេ (ឯកសារ អ.ស.ប លេខ A/51/930-S/1997/488 ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧)។ ស្ថានភាព



C C C E T C
CHAMBER CHAMBRE DE PREMIÈRE INSTANCE

ត្រូវបានទទួលស្គាល់ក្នុងខណៈនៃការបង្កើត អ.វ.ត.ក និងដោយសារមានហេតុផលនេះហើយ ទើប អ.វ.ត.ក ត្រូវបានបង្កើតឡើងជាលើកដំបូងនៅទីនេះ[៣៤]។

១៤. បើទោះបីជា អ.វ.ត.ក ត្រូវបានបង្កើតឡើង ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ និង ក្នុងគោលបំណងពង្រឹងសមត្ថភាពតុលាការជាតិនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ អ.វ.ត.ក មានលក្ខណៈពិសេសជាច្រើនខុសពីសាលាក្តី និងតុលាការដែលមានលក្ខណៈអន្តរជាតិផ្សេងៗទៀត។ ដូចបានលើកឡើងរួចមកហើយ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅតាមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានផ្តល់យន្តការណាមួយឲ្យ អ.វ.ត.ក តែងតាំង ដាក់វិន័យ ឬដកហូតចៅក្រមកម្ពុជាដោយផ្ទាល់នោះទេ។ នេះគឺជាលក្ខណៈកូនកាត់របស់ អ.វ.ត.ក ដែលផ្តល់ការទទួលខុសត្រូវអំពីឯករាជ្យភាពនេះទៅឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអង្គការសហប្រជាជាតិ នៅក្នុងការតែងតាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ។ អ.វ.ត.ក មិនមានទាំងអាណត្តិ និងយន្តការក្នុងការដោះស្រាយដោយផ្ទាល់នូវភាពខ្វះចន្លោះដូចដែលបានចោទប្រកាន់នៅក្នុងយន្តការជាតិ ក្នុងការធានាឯករាជ្យភាពតុលាការនោះទេ។ ទោះបីជាយ៉ាងក៏ដោយ អ.វ.ត.ក អាចជាតុលាការគំរូមួយ សម្រាប់ជួយជំរុញឲ្យមាន ការធានានូវឯករាជ្យភាព និងសុចរិតភាពនៅក្នុងស្ថាប័នតុលាការ។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របថា ការចោទប្រកាន់ដែលមាននៅក្នុងពាក្យបណ្តឹងជិតចិត្តត្រូវបានយកមកពិចារណាដោយយកចិត្តទុកដាក់បំផុត និង ទទួលស្គាល់នូវសារៈសំខាន់នៃការប្តេជ្ញាចិត្តយ៉ាងពិតប្រាកដពីខាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែទម្រង់សមត្ថភាពរបស់តុលាការ និងស្តារឲ្យមានជំនឿទុកចិត្តពេញលេញពីសាធារណជនឡើងវិញលើប្រព័ន្ធតុលាការ។

១៥. បើទោះបីជា អ.វ.ត.ក មិនអាចដោះស្រាយនូវបញ្ហាទូទៅអំពីឯករាជ្យភាព និង សុចរិតភាពរបស់តុលាការបានដោយផ្ទាល់ក៏ដោយ ក៏ អ.វ.ត.ក អាចធានាបានថា ក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ជនជាប់ចោទពិតជាទទួលបានអត្ថប្រយោជន៍ពីដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងបានប្រព្រឹត្តទៅស្របតាមបទដ្ឋានអន្តរជាតិ[៣៥]។ ក្នុងការធានាដល់សិទ្ធិរបស់ជនជាប់ចោទនៅ

---

សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា, ឯកសារ អ.ស.ប លេខ /RES/52/135 ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ កថាខណ្ឌ ៨ (ទទួលស្គាល់ថាមាន "ការប្រព្រឹត្តអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ" និងការទទួលស្គាល់អំពីតម្រូវការដើម្បី "បង្កើតប្រព័ន្ធយុត្តិធម៌មួយដែលមានដំណើរការទៅបាន និងមិនលម្អៀង")។

[៣៤] ចរិតលក្ខណៈជាអន្តរជាតិរបស់ អ.វ.ត.ក ត្រូវបានគេទទួលស្គាល់ថា ជាការទប់ទល់នឹងកង្វះ[illegible]ត្រូវបានគេដឹងឮយ៉ាងច្បាស់នៅក្នុងប្រទេសកម្ពុជា នៅពេលដែល អ.វ.ត.ក ត្រូវបានបង្កើតឡើង (កថាខណ្ឌ ៣២ នៃបណ្តឹងជិតចិត្ត)។

[៣៥] កថាខណ្ឌ ៣០ ដល់ ៣៧ នៃបណ្តឹងជិតចិត្ត។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

ចំពោះមុខ អ.វ.ត.ក វិធាន ៣៤ នៃវិធានផ្ទៃក្នុងបានការពារដល់សុចរិតភាពនៃរឿងក្ដីជាក់លាក់នៅចំពោះមុខខ្លួន។ អង្គបុរេជំនុំជម្រះមានភារកិច្ចទទួលខុសត្រូវនៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ ។

## III. សេចក្ដីសម្រេចបញ្ចប់

១៦. ដូចបានបង្ហាញខាងលើ បណ្ដឹងជំទាស់ចោទប្រកាន់តែពីការលេចឡើងនូវភាពលម្អៀង ដោយសំអាងទៅលើទស្សនៈយល់ឃើញជាអវិជ្ជមានរបស់សាធារណជន ដែលអាចកើតចេញពីចំណុចខ្វះខាត នៅក្នុងប្រព័ន្ធតុលាការកម្ពុជាប៉ុណ្ណោះ[៣៦]។ ដូច្នេះ ដូចបានបង្ហាញខាងលើ តាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងដែលស្របជាមួយយុត្តិសាស្ត្រអន្តរជាតិ បណ្ដឹងជំទាស់នេះមិនមានលក្ខណៈសមស្របឡើយ ។ ប្រសិនបើការប្ដឹងចោទប្រកាន់ចំពោះបុគ្គលអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវក្នុងការបំពេញមុខងារជាចៅក្រមនោះ ត្រូវអនុវត្តតាមយន្តការជាតិក្នុងការកំណត់ស្ដង់ដារអំពីសុចរិតភាពនៅក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះសាលាដំបូងសូមសង្កត់ធ្ងន់ទៅលើតម្រូវការឲ្យមានយន្តការបែបនេះ ដើម្បីប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងប្រកបដោយសមភាព ក្នុងគោលបំណងធានាឲ្យមានជំនឿទុកចិត្តពីសាធារណជនលើតុលាការ និងដើម្បីពង្រឹងនីតិរដ្ឋក្នុងប្រទេសកម្ពុជា។

១៧. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បណ្ដឹងជំទាស់មិនបានលើកឡើង ឬបង្ហាញឲ្យឃើញថា លោកចៅក្រម និល ណុន មានភាពលម្អៀង ទាក់ទងនឹងសំណុំរឿងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះទេ។ ដូចបានទទួលស្គាល់ក្នុងបណ្ដឹងជំទាស់ស្រាប់ គឺមិនមានហានិភ័យនៃការប្រព្រឹត្តិមិនត្រឹមត្រូវកើតមាននៅក្នុងសំណុំរឿងបច្ចុប្បន្ននោះទេ[៣៧]។ ហេតុដូច្នេះ ក្នុងរយៈពេលកន្លងមកនេះ មិនមានអ្នកសង្កេតការណ៍ណាម្នាក់ទទួលបានព័ត៌មានអំពីកាលៈទេសៈពាក់ព័ន្ធអំពីភាពលំអៀងនៅក្នុងសំណុំរឿង ០០២ នោះទេ។ ហេតុដូច្នេះ បណ្ដឹងជំទាស់នេះត្រូវបានបដិសេធចោល ដោយសារថា បណ្ដឹងជំទាស់នេះមិនជាប់ទាក់ទងទៅនឹងភាពលម្អៀងរបស់ចៅក្រម ហើយក៏មិនបានលើកឡើងឲ្យបានចំៗ អំពីភាពលម្អៀងនៅក្នុងរឿងក្ដីប្រឆាំងនឹងជនជាប់ចោទនោះដែរ។ ដោយការខកខានមិនបានបំពេញលក្ខខណ្ឌតម្រូវសម្រាប់ដំណោះស្រាយតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង នោះសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរមិនពាក់ព័ន្ធឡើយ។

---

[៣៦] កថាខណ្ឌ ៣២ នៃបណ្ដឹងជំទាស់៖ ("មេធាវីការពារក្ដីលើកឡើងថា [ការជូនជាសំណូកពីសំណាក់ក្រសួងយុត្តិធម៌ ឬព្រះរាជអាជ្ញា ឬដើមបណ្ដឹងរដ្ឋប្បវេណី ទៅឲ្យចៅក្រម និល ណុន ដើម្បីជាថ្នូរនឹងសេចក្ដីសម្រេចគួរជាទីពេញចិត្ត នាពេលជំនុំជម្រះក្ដី] គឺមិនគួរឲ្យជឿ ...")។

**តាមសំអាងហេតុដូចបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច ៖**

**បដិសេធ** សំណើសុំពន្យាពេលដាក់សារណាតបរបស់សហព្រះរាជអាជ្ញា ដោយសារអំឡុងពេលកំណត់សម្រាប់ធ្វើសារណាត្រូវបានកន្លងហួស។

**បដិសេធ** បណ្តឹងមិនចិត្តនេះចោល។

**បដិសេធ** សំណើសុំឱ្យបើកសវនាការជាសាធារណៈទៅលើបណ្តឹងមិនចិត្ត និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ។

**ច្រានចោល** សំណូមពរទាំងអស់ដែលមាននៅក្នុងបណ្តឹងមិនចិត្ត និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយសារតែមិនមានការពាក់ព័ន្ធ និង

**បង្គាប់** ឱ្យផ្នែកគ្រប់គ្រងតុលាការចាត់ថ្នាក់ឯកសារទាំងអស់ ដែលបានដាក់ជូនជាឯកសារសម្ងាត់ទាក់ទងនឹងបណ្តឹងមិនចិត្ត និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ជាឯកសារសាធារណៈវិញ។

យោងតាមវិធាន ៣៤(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **ធូ មណី**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **យូរ ឧត្តរា**